ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៨៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩២ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់របនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដំឡើងនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុលទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុលនិងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ សរសេរកាត់ថា "**ក.ជ.គ.**" ដែលត្រូវស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលបំណងដូចខាងក្រោម÷

- រៀបចំបេសកកម្ម សមាសភាព និងការប្រព្រឹត្តទៅរបស់ **ក.ជ.គ.**
- រៀបចំមុខងារនិងភារកិច្ចរបស់អង្គភាពនានានៃ **ក.ជ.គ.**
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារគ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះ **ក.ជ.គ.** អគ្គលេខាធិការដ្ឋាននិងគ្រប់អង្គភាពក្រោមឱវាទ **ក.ជ.គ.**។

## ជំពូកទី ២

## បេសកកម្ម សមាសភាព និងការប្រព្រឹត្តទៅនៃ គ.ជ.គ.

**មាត្រា ៤.-**

**គ.ជ.គ.** បំពេញការងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងនិងអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម តាមរយៈការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃនូវគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**មាត្រា ៥.-**

**គ.ជ.គ.** មានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១- រដ្ឋមន្ត្រី ឬតំណាងជាឥស្សរជនជាន់ខ្ពស់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | ប្រធាន |
| ២- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | អនុប្រធាន |
| ៣- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| ៤- តំណាងអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួង ស.ហ.វ. | ១រូប | សមាជិក |
| ៥- តំណាងអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួង ស.ហ.វ. | ១រូប | សមាជិក |
| ៦- តំណាងធនាគារជាតិនៃកម្ពុជា | ១រូប | សមាជិក |
| ៧- តំណាងគណៈកម្មការមូលបត្រកម្ពុជា | ១រូប | សមាជិក |
| ៨- តំណាងក្រសួងអប់រំ យុវជន និងកីឡា | ១រូប | សមាជិក |
| ៩- តំណាងក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| ១០- តំណាងវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា | ១រូប | សមាជិក |
| ១១- អគ្គលេខាធិការ **គ.ជ.គ.** | | សមាជិក |
| ១២- តំណាងសភាពាណិជ្ជកម្មយ៉ាងតិច | ១រូប | សមាជិកពិគ្រោះយោបល់ |
| ១៣-តំណាងសហព័ន្ធសមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជាយ៉ាងតិច | ១រូប | សមាជិកពិគ្រោះយោបល់ |
| ១៤-តំណាងសមាគមធនាគារយ៉ាងតិច | ១រូប | សមាជិកពិគ្រោះយោបល់ |
| ១៥- តំណាងសមាគមមីក្រូហិរញ្ញវត្ថុយ៉ាងតិច | ១រូប | សមាជិកពិគ្រោះយោបល់ |
| ១៦- តំណាងសមាគមធានារ៉ាប់រងយ៉ាងតិច | ១រូប | សមាជិកពិគ្រោះយោបល់ |
| ១៧- អ្នកជំនាញគណនេយ្យនិងសវនកម្មយ៉ាងតិច | ៤រូប | សមាជិកពិគ្រោះយោបល់។ |

សមាសភាពជាក្រសួង ស្ថាប័ន ដែលត្រូវចាត់តំណាងមកចូលរួមនៅក្នុង **គ.ជ.គ.** អាចត្រូវបានកែសម្រួលតាមរយៈអនុក្រឹត្យតាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ **គ.ជ.គ.** ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សមាជិកពិគ្រោះយោបល់ ត្រូវបានតែងតាំងជាសមាសភាព **គ.ជ.គ.** តាមការចាំបាច់ដើម្បីចូលរួមផ្តល់យោបល់ តែពុំមានសិទ្ធិចូលរួមបោះឆ្នោតធ្វើសេចក្តីសម្រេចឡើយ។

តំណាងរបស់ក្រសួងនិងស្ថាប័ន ដែលជាសមាសភាពនៃ **គ.ជ.គ.** ត្រូវមានសញ្ញាបត្រថ្នាក់ឧត្តមសិក្សា មានជំនាញនិងបទពិសោធន៍ពាក់ព័ន្ធនឹងគណនេយ្យ សវនកម្ម ឬហិរញ្ញវត្ថុ យ៉ាងតិច៥(ប្រាំ)ឆ្នាំ។

មុខងារ ភារកិច្ច និងសិទ្ធិ របស់សមាជិកពិគ្រោះយោបល់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ៦.-**

អនុប្រធាន និងសមាជិក **គ.ជ.គ.** មានអាណត្តិកំណត់រយៈពេល៥(ប្រាំ)ឆ្នាំ ហើយអាចត្រូវតែងតាំងសាជាថ្មីទៀតបានសម្រាប់១(មួយ)អាណត្តិទៀត។

**មាត្រា ៧.-**

ប្រធាន អនុប្រធាន សមាជិក ឬសមាជិកពិគ្រោះយោបល់ **គ.ជ.គ.** អាចត្រូវបានដកហូត ឬផ្លាស់ប្តូរភារកិច្ចនៅមុនពេលផុតអាណត្តិ ដោយមូលហេតុណាមួយដូចខាងក្រោម÷

- ការបាត់បង់ការងារពីស្ថាប័នដែលខ្លួនតំណាង
- ការលាលែងពីសមាជិកភាពដោយសាមីខ្លួនស្នើសុំ
- ការបាត់បង់សមត្ថភាពការងារ
- ការមិនចូលរួមប្រជុំចំនួន៣ (បី)ដងជាប់ៗគ្នា ដោយគ្មានមូលហេតុសមស្រប
- មរណភាព។

ក្នុងករណីណាមួយខាងលើ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើសំណើទៅក្រសួង ស្ថាប័នសាមីដើម្បីឱ្យចាត់បញ្ជូនតំណាងដែលត្រូវមកជំនួស រួចស្នើតែងតាំងបន្តទៅរាជរដ្ឋាភិបាល។

**មាត្រា ៨.-**

ប្រធាន អនុប្រធាន សមាជិក និងសមាជិកពិគ្រោះយោបល់ **គ.ជ.គ.** ព្រមទាំងលេខាកត់ត្រាក្នុងកិច្ចប្រជុំ ត្រូវទទួលបានលាភការ ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ៩.-**

កិច្ចប្រជុំរបស់ **គ.ជ.គ.** មានការប្រជុំសាមញ្ញនិងការប្រជុំវិសាមញ្ញ។

**មាត្រា ១០.-**

**គ.ជ.គ.** ត្រូវធ្វើការប្រជុំសាមញ្ញយ៉ាងតិចមួយដងក្នុង១(មួយ)ត្រីមាស ទៅតាមការអញ្ជើញរបស់ប្រធាន **គ.ជ.គ.**។ ក្នុងករណីចាំបាច់និងបន្ទាន់ **គ.ជ.គ.** អាចបើកការប្រជុំវិសាមញ្ញបានគ្រប់ពេលវេលា ដើម្បីជាប្រយោជន៍ដល់វិស័យគណនេយ្យនិងសវនកម្មនៅព្រះរាជាណាចក្រកម្ពុជា តាមសំណើរបស់ប្រធាន **គ.ជ.គ.** ឬតាមសំណើជាលាយលក្ខណ៍អក្សររបស់អគ្គលេខាធិការនៃ **គ.ជ.គ.** ឬតាមសំណើពីសមាជិក **គ.ជ.គ.** ដែលមាន

ចំនួនយ៉ាងតិច១ភាគ៣ នៃសមាជិកទាំងអស់ ក្រៅពីសមាជិកពិគ្រោះយោបល់។ ក្នុងករណីប្រធាន **គ.ជ.គ.** អវត្តមាន អនុប្រធាន **គ.ជ.គ.** ត្រូវដឹកនាំការប្រជុំជំនួសតាមការផ្ទេរសិទ្ធិរបស់ប្រធាន។

**មាត្រា ១១.-**

កិច្ចប្រជុំរបស់ **គ.ជ.គ.** អាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពី ៥០(ហាសិប) ភាគរយនៃសមាជិកទាំងអស់ ក្រៅពីសមាជិកពិគ្រោះយោបល់។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសខ្លួនបានឡើយ។ ក្នុងករណីដែលកិច្ចប្រជុំលើកទីមួយមិនអាចប្រព្រឹត្តទៅបានដោយមូលហេតុខ្វះកូរ៉ុម ប្រធានអាចកោះអញ្ជើញប្រជុំម្តងទៀតជាលើកទីពីរបាន ក្នុងរយៈពេលយ៉ាងតិច១០(ដប់)ថ្ងៃក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំលើកទីមួយ។ ការប្រជុំលើកទីពីរនេះ មិនតម្រូវឱ្យមានសមាជិកគ្រប់ចំនួនកូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈដែលខកខានមិនបានប្រជុំតាមការអញ្ជើញលើកទីមួយប៉ុណ្ណោះ។

សេចក្តីសម្រេចរបស់ **គ.ជ.គ.** អាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសម្លេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធាននៃកិច្ចប្រជុំមានឧត្តមានុភាព។

**មាត្រា ១២.-**

រាល់កិច្ចប្រជុំរបស់ **គ.ជ.គ.** ត្រូវមានកំណត់ហេតុ។

សេចក្តីសម្រេចរបស់ **គ.ជ.គ.** ត្រូវកត់ត្រាក្នុងកំណត់ហេតុដែលត្រូវចុះហត្ថលេខាដោយប្រធាននៃកិច្ចប្រជុំ និងលេខាកត់ត្រា។ កំណត់ហេតុនេះត្រូវផ្ញើជូនប្រធាន អនុប្រធាន និងសមាជិកទាំងអស់ **គ.ជ.គ.** ក្នុងរយៈពេលយ៉ាងយូរ ១០(ដប់)ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំ។

**មាត្រា ១៣.-**

ក្នុងករណីដែលកិច្ចប្រជុំ **គ.ជ.គ.** សម្រេចលើសេចក្តីព្រាងច្បាប់ អនុក្រឹត្យ បទបញ្ជា ឬស្តង់ដាគណនេយ្យ ឬស្តង់ដាសវនកម្មដែលទាក់ទងនឹងវិស័យសកម្មភាពណាមួយ **គ.ជ.គ.** អាចស្នើសុំឱ្យរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាធារណៈឬឯកជនចាត់តំណាងជាអ្នកបច្ចេកទេសពាក់ព័ន្ធដែលមិនមែនជាសមាជិក **គ.ជ.គ.** ឱ្យចូលរួមក្នុងកិច្ចប្រជុំ **គ.ជ.គ.** បាន។

**មាត្រា ១៤.-**

ប្រធាន **គ.ជ.គ.** ត្រូវរាយការណ៍ជាប្រចាំអំពីការអភិវឌ្ឍ គោលនយោបាយ និងយុទ្ធសាស្ត្រ ព្រមទាំងបញ្ហាប្រឈមនានាក្នុងវិស័យគណនេយ្យនិងសវនកម្ម ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា ១៥.-**

**គ.ជ.គ.** ត្រូវមានបទបញ្ជាផ្ទៃក្នុង ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ប្រធាន **គ.ជ.គ.**។

**មាត្រា ១៦.-**

**គ.ជ.គ.** មាននិមិត្តសញ្ញានិងត្រាដោយឡែក ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

## ជំពូកទី ៣
## អគ្គលេខាធិការដ្ឋាន នៃ គ.ជ.គ.

**មាត្រា ១៧.-**

**គ.ជ.គ.** ត្រូវមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការរដ្ឋបាលនិងបច្ចេកទេសអចិន្ត្រៃយ៍។ អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូប ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ អមដោយអគ្គលេខាធិការរងអនុលោមតាមបទប្បញ្ញត្តិជាធរមាន ដែលត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា ១៨.-**

អគ្គលេខាធិការដ្ឋាននៃ **គ.ជ.គ.** មានមុខងារនិងភារកិច្ចដូចតទៅ÷

- ទទួលបន្ទុកការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុរបស់ **គ.ជ.គ.**
- រៀបចំកិច្ចប្រជុំរបស់ **គ.ជ.គ.**
- រៀបចំយុទ្ធសាស្ត្រនិងផែនការនានាដើម្បីអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម
- រៀបចំគម្រោងថវិកានិងគ្រប់គ្រងចំណូល ចំណាយរបស់ **គ.ជ.គ.**
- រៀបចំ និងគ្រប់គ្រងកិច្ចការអាជ្ញាបណ្ណជូនគណនេយ្យករនិងសវនករ ដើម្បីដាក់ជូន **គ.ជ.គ.** ពិនិត្យនិងសម្រេច
- ធ្វើជាតំណាងឱ្យ **គ.ជ.គ.** នៅចំពោះមុខតុលាការ
- ធ្វើជាសេនាធិការបច្ចេកទេសរបស់ **គ.ជ.គ.**
- អនុវត្តការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា
- លើកសំណើវិធានការចំពោះរាល់ការបំពានច្បាប់គណនេយ្យនិងសវនកម្ម លិខិតបទដ្ឋានពាក់ព័ន្ធនឹងគណនេយ្យនិងសវនកម្ម និងស្តង់ដាគណនេយ្យនិងសវនកម្ម ព្រមទាំងរៀបចំសេចក្តីសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មពិន័យអន្តរការណ៍ជូន **គ.ជ.គ.** ពិនិត្យនិងសម្រេច
- ធ្វើជាតំណាង **គ.ជ.គ.** ក្នុងទំនាក់ទំនងជាមួយតតិយជន ដូចជាអង្គការជាតិនិងអន្តរជាតិ ព្រមទាំងវិស័យឯកជន ក្នុងគោលដៅពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងស្តង់ដានានានិងក្នុងគោលដៅជំរុញកិច្ចអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម
- ទទួលបណ្តឹងតវ៉ាផ្សេងៗ ហើយសិក្សានិងលើកយោបល់ជូន **គ.ជ.គ.** ដើម្បីសម្រេចលើវិធានការសមស្រប
- ជំរុញឱ្យមានមូលដ្ឋានទិន្នន័យពីបណ្តាសហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញសម្រាប់ជា មូលដ្ឋានក្នុងការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តច្បាប់និងស្តង់ដាពាក់ព័ន្ធ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ **គ.ជ.គ.** ដើម្បីដាក់ជូន **គ.ជ.គ.** ពិនិត្យនិងសម្រេច

- រៀបចំខ្លឹមសារនៃការពិគ្រោះយោបល់របស់ **គ.ជ.គ.** ជាមួយស្ថាប័នឬអង្គការជាតិនិងអន្តរជាតិជាដៃគូនានា
- លើកសំណើជូន **គ.ជ.គ.** ដើម្បីពិនិត្យ ពិភាក្សា និងសម្រេចលើសេចក្តីព្រាងច្បាប់ អនុក្រឹត្យ ស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម ព្រមទាំងធ្វើបច្ចុប្បន្នកម្មនៃស្តង់ដាទាំងនោះនិងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត នៅក្នុងដែនសមត្ថកិច្ចរបស់ **គ.ជ.គ.**
- អនុវត្តការងារផ្សេងទៀត ដែលប្រធាន **គ.ជ.គ.** ប្រគល់ជូន។

**មាត្រា ១៩.-**

អគ្គលេខាធិការដ្ឋាន **គ.ជ.គ.** មាននាយកដ្ឋានក្រោមឱវាទ ដូចតទៅ÷

- នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ
- នាយកដ្ឋានអនុលោមភាពនិងត្រួតពិនិត្យ
- នាយកដ្ឋានកិច្ចការច្បាប់
- នាយកដ្ឋានបច្ចេកទេស។

នាយកដ្ឋាននីមួយៗ ត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន ១(មួយ)រូប អមដោយអនុប្រធាននាយកដ្ឋានអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា ២០.-**

នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុបំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** លើការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ ព័ត៌មានវិទ្យា និងផែនការថវិកា។

នាយកដ្ឋានអនុលោមភាព និងត្រួតពិនិត្យ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** លើការងារអនុលោមភាព ការជំរុញការអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម និងការងារត្រួតពិនិត្យគុណភាពសវនកម្ម។

នាយកដ្ឋានកិច្ចការច្បាប់ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** លើការងារនីតិកម្ម វិវាទ ស្ថិតិ និងកិច្ចការអន្តរជាតិ។

នាយកដ្ឋានបច្ចេកទេស បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** លើការងារស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម និងស្តង់ដាពាក់ព័ន្ធប្រហាក់ប្រហែល ព្រមទាំងការងារអភិវឌ្ឍវិជ្ជាជីវៈ ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ។

អង្គការលេខរបស់ **គ.ជ.គ.** ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២១.-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី ៤
## ការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋ

**មាត្រា ២២.-**

ប្រភពធនធាននិងថវិការបស់ **គ.ជ.គ.** រួមមាន÷

- ថវិកាជាតិដែលផ្តល់ឱ្យ **គ.ជ.គ.**
- ថវិកាដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការបរទេសនិងពីប្រភពផ្សេងទៀត ដែល **គ.ជ.គ.** មានសិទ្ធិទទួលនិងគ្រប់គ្រងដោយផ្ទាល់ សម្រាប់ចំណាយលើការស្រាវជ្រាវ ការបណ្តុះបណ្តាល មធ្យោបាយធ្វើការងារ និងសេវារដ្ឋបាលនិងបច្ចេកទេសជាដើម។

ក្រៅពីធនធាននិងថវិកា ដូចមានចែងក្នុងកថាខ័ណ្ឌទី១ខាងលើ **គ.ជ.គ.** ក៏មានប្រភពធនធានផ្សេងទៀតពី÷

- ថវិកាដែលបានមកពីការលក់សិទ្ធិនិពន្ធ ការបោះពុម្ពផ្សាយ និងពីការបើកវគ្គបណ្តុះបណ្តាល ការប្រជុំ និងផ្សព្វផ្សាយ
- កម្រៃសេវាពាក់ព័ន្ធផ្សេងៗ
- ប្រាក់ពិន័យអន្តរការណ៍លើបុគ្គលដែលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងគណនេយ្យនិងសវនកម្ម។

ការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋរបស់ **គ.ជ.គ.** ត្រូវគោរពតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា ២៣.-**

**គ.ជ.គ.** ត្រូវទទួលរងអធិការកិច្ចនិងសវនកម្ម ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**មាត្រា ២៤.-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលត្រូវបានដាក់ឱ្យអនុវត្ត ដោយផ្អែកលើមូលដ្ឋាននៃអនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីសមាសភាពនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ ត្រូវបន្តអានុភាពគតិយុត្តរហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ២៥.-**

អនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីសមាសភាពនិងការរៀបចំនៃក្រុមប្រឹក្សាជាតិគណនេយ្យត្រូវទុកជានិរាករណ៍និងត្រូវជំនួសទាំងស្រុងដោយអនុក្រឹត្យនេះ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៨៥អនក្រ.បក
ចុះថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០១៧
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ

## អង្គការលេខរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ

